**កិច្ចប្រជុំជាសាធារណៈស្តីពីសំណើដាក់លក់ VERITY HEALTH SYSTEM, ST. FRANCIS MEDICAL CENTER, ST. VINCENT MEDICAL CENTER, SETON MEDICAL CENTER, និង SETON COASTSIDE**

អគ្គរដ្ឋអាជ្ញាកំពុងពិនិត្យឡើងវិញនូវសំណើដាក់លក់មជ្ឈមណ្ឌល St. Francis Medical Center ដែលជាមន្ទីរពេទ្យថែទាំអ្នកជំងឺធ្ងន់ទូទៅ មានគ្រែទទួលបានអាជ្ញាប័ណ្ណសម្រាប់ការសម្រាកព្យាបាលចំនួន 314 គ្រែ មានទីតាំងនៅទីក្រុង Lynwood រដ្ឋ California, មជ្ឈមណ្ឌល St. Vincent Medical Center ដែលជាមន្ទីរពេទ្យថែទាំអ្នកជំងឺធ្ងន់ទូទៅ មានគ្រែទទួលបានអាជ្ញាប័ណ្ណសម្រាប់ការសម្រាកព្យាបាលចំនួន 339 គ្រែ មានទីតាំងនៅទីក្រុង Los Angeles រដ្ឋ California, មជ្ឈមណ្ឌល Seton Medical Center ដែលជាមន្ទីរពេទ្យថែទាំអ្នកជំងឺធ្ងន់ទូទៅ មានគ្រែទទួលបានអាជ្ញាប័ណ្ណសម្រាប់ការសម្រាកព្យាបាលចំនួន 250 គ្រែ មានទីតាំងនៅទីក្រុង Daly City រដ្ឋ California និងមន្ទីរពេទ្យ Seton Coastside ដែលជាមន្ទីរពេទ្យថែទាំអ្នកជំងឺធ្ងន់ទូទៅ មានគ្រែទទួលបានអាជ្ញាប័ណ្ណសម្រាប់ការសម្រាកព្យាបាលចំនួន 5 គ្រែ និងគ្រែទទួលបានអាជ្ញាប័ណ្ណបំពាក់ដោយបរិក្ខារវេជ្ជសាស្ត្រជំនាញចំនួន 116 គ្រែ មានទីតាំងនៅទីក្រុង Moss Beach រដ្ឋ California។ "កិច្ចព្រមព្រៀងទិញទ្រព្យសកម្ម (Asset Purchase Agreement)" រវាងក្រុមហ៊ុន Verity Health System of California, Inc. ដែលជាក្រុមហ៊ុនបម្រើផលប្រយោជន៍សាធារណៈមិនរកប្រាក់កម្រៃនៃរដ្ឋកាលីហ្វ័រញ៉ា, ក្រុមហ៊ុន Verity Holdings LLC ដែលជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតនៃរដ្ឋកាលីហ្វ័រញ៉ា មជ្ឈមណ្ឌល St. Francis Medical Center ដែលជាក្រុមហ៊ុនបម្រើផលប្រយោជន៍សាធារណៈមិនរកប្រាក់កម្រៃនៃរដ្ឋកាលីហ្វ័រញ៉ា, មជ្ឈមណ្ឌល St. Vincent Medical Center ដែលជាក្រុមហ៊ុនបម្រើផលប្រយោជន៍សាធារណៈមិនរកប្រាក់កម្រៃនៃរដ្ឋកាលីហ្វ័រញ៉ា, ក្រុមហ៊ុន St. Vincent Dialysis Center, Inc., ដែលជាក្រុមហ៊ុនបម្រើផលប្រយោជន៍សាធារណៈមិនរកប្រាក់កម្រៃនៃរដ្ឋកាលីហ្វ័រញ៉ា, និងមជ្ឈមណ្ឌល Seton Medical Center ដែលជាក្រុមហ៊ុនបម្រើផលប្រយោជន៍សាធារណៈមិនរកប្រាក់កម្រៃនៃរដ្ឋកាលីហ្វ័រញ៉ា ជាភាគីអ្នកលក់ ជាមួយនឹងក្រុមហ៊ុន Strategic Global Management, Inc., ដែលជាក្រុមហ៊ុនរកប្រាក់កម្រៃនៃរដ្ឋកាលីហ្វ័រញ៉ា ជាភាគីអ្នកទិញ។ សំណើការទិញលក់មន្ទីរពេទ្យដែលរកប្រាក់កម្រៃនេះ កំពុងត្រូវបានត្រួតពិនិត្យក្រោមក្រមសាជីវកម្មរដ្ឋកាលីហ្វ័រញ៉ា ផ្នែក 5914 និងមាត្រាផ្សេងទៀត (California Corporations Code Section 5914 et seq.) និងកំពុងត្រួតពិនិត្យក្រោមចំណងជើងច្បាប់ទី 11 នៃក្រមបទប្បញ្ញត្តិរដ្ឋកាលីហ្វ័រញ៉ា ផ្នែក 999.5 ផ្នែករង (h) (Title 11, California Code of Regulations, Section 999.5, subdivision (h)) ដែលជាសំណើរមួយដើម្បីធ្វើការកែប្រែលក្ខខណ្ឌពីមុនដែលបានចេញដោយអគ្គរដ្ឋអាជ្ញានៅថ្ងៃទី3 ខែធ្នូ ឆ្នាំ2015។

លក្ខខណ្ឌនៃសំណើដាក់លក់នេះ មានចែងនៅក្នុងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គរដ្ឋអាជ្ញា។ ប្រសិនបើអ្នកចង់ស្នើសុំសំណៅចតចម្លងមួយច្បាប់នៃសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរនេះនៅក្នុងស៊ីឌី សូមទាក់ទង Scott Chan តាមរយៈ scott.chan@doj.ca.gov ឬតាមទូរសព្ទទៅលេខ (415) 415-510-3430 និងផ្តល់ឈ្មោះ និងអាសយដ្ឋានប្រៃសណីយ៍របស់អ្នក។ សំណៅចតចម្លងនៃសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរនេះក៏មានផ្តល់ជូនសម្រាប់ការពិនិត្យឡើងវិញផងដែរក្នុងអំឡុងម៉ោងធ្វើការធម្មតានៅតាមទីតាំងដូចខាងក្រោម៖

| | |
|---|---|
| Verity Health System<br>ការិយាល័យក្រុមហ៊ុន<br>រដ្ឋបាល – Jessica Davis<br>2040 E Mariposa Avenue<br>El Segundo, CA 90245 | Verity Health System<br>ការិយាល័យក្រុមហ៊ុន<br>រដ្ឋបាល – Jessica Davis<br>2040 E Mariposa Avenue<br>El Segundo, CA 90245 |
| St. Francis Medical Center<br>រដ្ឋបាល<br>ការិយាល័យនាយកប្រតិបត្តិ – Stephanie Kopp<br>Medical Office Plaza<br>3628 E. Imperial Hwy, Suite 400<br>Lynwood, CA 90262 | St. Vincent Medical Center<br>រដ្ឋបាល<br>ការិយាល័យនាយកប្រតិបត្តិ – Robert Yesko<br>2131 W 3rd St.<br>Los Angeles, CA 90057 |
| Seton Medical Center<br>រដ្ឋបាល<br>ការិយាល័យនាយកប្រតិបត្តិ<br>1900 Sullivan Ave.<br>Daly City, CA 94015 | Seton Medical Center – Coastside<br>ការិយាល័យរដ្ឋបាល<br>600 Marine Blvd<br>Moss Beach, CA 94038 |

សំណៅថតចម្លងនៃសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរនេះ ក៏អាចរកបានផងដែរនៅលើគេហទំព័រ ដូចខាងក្រោម៖

https://verity.org/
https://seton.verity.org/SMC/
https://setoncoastside.verity.org/SMCC/
https://stfrancis.verity.org/SFMC/
https://stvincent.verity.org/SVMC/

នៅថ្ងៃទី31 ខែសីហា ឆ្នាំ2018 ក្រុមហ៊ុន Verity Health System of California, Inc. និងក្រុមហ៊ុនបុត្តសម្ព័ន្ធជាក់លាក់មួយចំនួនរបស់ខ្លួន បានដាក់សំណើសុំការអនុគ្រោះស្ថិតក្រោមជំពូកទី 11 នៃចំណងជើងច្បាប់ទី 11 នៃក្រមបទប្បញ្ញត្តិសហរដ្ឋអាមេរិក ហើយឯកសារនានាដែលពាក់ព័ន្ធនឹងករណីក្ស័យធន រួមទាំងសំណៅថតចម្លងនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលមានយោងនៅផ្នែកខាងលើ អាចស្វែងរកបាននៅគេហទំព័រនេះ៖ www.kccllc.net/verityhealth/

អគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ា នឹងបើកកិច្ចប្រជុំជាសាធារណៈចាប់ពីម៉ោង 10:00 ព្រឹក នៅក្នុងកាលបរិច្ឆេទដូចខាងក្រោម៖

នៅថ្ងៃទី26 ខែសីហា ឆ្នាំ2019 នៅ Bateman Hall Auditorium មានទីតាំងនៅ
11331 Ernestine Ave., Lynwood, CA 90262។

នៅថ្ងៃទី27 ខែសីហា ឆ្នាំ2019 នៅ Seton Hall Auditorium មានទីតាំងនៅ
262 South Lake Street, Los Angeles, CA 90057។

គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីធ្វើទទួលបាននូវមតិយោបល់អំពីសំណើសុំដាក់លក់មន្ទីរពេទ្យ និងបរិក្ខារវេជ្ជសាស្ត្រ និងដើម្បីធ្វើការពិចារណាអំពីរបាយការណ៍នៃផលប៉ះពាល់ចំពោះការថែទាំសុខភាព ដែលរៀបចំដោយអ្នកប្រឹក្សាយោបល់ ដោយមានការចូលរួមពីអគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ា។ នៅមុនពេលកិច្ចប្រជុំជាសាធារណៈនេះ របាយការណ៍នៃផលប៉ះពាល់ចំពោះការថែទាំសុខភាព នឹងអាចស្វែងរកបាននៅលើគេហទំព័ររបស់អគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ានៅ http://www.oag.ca.gov/charities/nonprofithosp។

បុគ្គលនានាអាចបង្ហាញពីទស្សនៈយល់ឃើញរបស់ពួកគេ (និងទទួលបានការលើកទឹកចិត្តឲ្យធ្វើបែបនេះ) ចំពោះដំណើរការទិញលក់នេះជាលាយលក្ខណ៍អក្សរទៅកាន់ការិយាល័យអគ្គរដ្ឋអាជ្ញានៃរដ្ឋកាលីហ្វ័រញ៉ាក្នុងទម្រង់អេឡិចត្រូនិកតាមរយៈលេខ (415) 510-3430 ឬផ្ញើសំណៅថតចម្លងនោះតាមប្រៃសណីយ៍ទៅកាន់ Scott Chan អគ្គរដ្ឋអាជ្ញារង តាមអាសយដ្ឋាន 455 Golden Gate Avenue, Suite 11000, San Francisco, CA 94102។ រយៈពេលផុតកំណត់នៃការទទួលមតិយោបល់ជាលាយលក្ខណ៍នេះ គឺនៅថ្ងៃទី30 ខែសីហា ឆ្នាំ2019។